**ទស្សនវិស័យៈ** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា

**Vision:** Sustainable and democratic development for Cambodia

# កំណត់ហេតុ

## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី៤៦

**របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅ
ក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ**

*ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២*

*ម៉ោង ៨:៣០ ដល់ ១២:០០ ថ្ងៃត្រង់*

*តាមរយៈការចូលរួមផ្ទាល់ និងតាមប្រព័ន្ធអនឡាញ* ***Zoom Meeting***

ទីតាំងមជ្ឈមណ្ឌលដាយកូនៀ





## ១. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែ កុម្ភៈ ឆ្នាំ២០២២ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន ១៨៥។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៤ ពីឆ្នាំ២០២១ ដល់ ២០២៣។ កម្មវិធីនេះ មានគោលបំណងសំខាន់ចំនួនពីរៈ ទី១ គឺធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និងទី២ មជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាព សម្រាប់អង្គការសង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ថ្មីៗនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញ ប្រកាសអន្តរក្រសួង (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីកំណត់ថ្ងៃនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ យ៉ាងណាមិញ អង្គការក្នុងស្រុក និងអង្គការបរទេសដែលកំពុងប្រតិបត្តិការងារនៅក្នុងប្រទេសកម្ពុជា នៅពុំទាន់យល់ដឹងស៊ីជម្រៅអំពីខ្លឹមសារប្រកាសអន្តរក្រសួងនៅឡើយទេ។

ដើម្បីឱ្យអង្គការសង្គមស៊ីវិលអាចមានលទ្ធភាពគ្រប់គ្រាន់អនុលោមតាមសេចក្តីប្រកាសនេះ និងពិសេសមានឱកាសចែករំលែកបទពិសោធន៍ និងមេរៀនល្អៗ អង្គការ គ.ស.ក នឹងរៀបចំវេទិការៀនសូត្រស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ វេទិកានេះ នឹងប្រព្រឹត្តឡើងនាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលដាយកូនៀ អាសយដ្ឋានផ្ទះលេខ ១៩ ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

## ២. ដំណើរការ និងលទ្ធផល

ជាដំបូង **អ្នកស្រី ភោគ ស្រីពេជ្រ** មន្ត្រីផ្នែកអភិបាលកិច្ច និងប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈនៃអង្គការ គសក ជាអ្នកសម្របសម្រួលបានណែនាំអំពីគោលការណ៍មួយចំនួននៃការប្រើប្រាស់ ***Zoom Meeting*** ក្នុងគោលបំណងអោយ វេទិការៀនសូត្រនេះដំណើរការទៅបានល្អ។

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស**ដែលអញ្ជើញមកពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលមានអ្នកចូលរួម សរុបចំនួន ១៨៦ នាក់ (ស្ត្រី១១៦នាក់) មកពីអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាលអន្តរដែលជាសមាជិក និងមិនមែនជាសមាជិករបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងមានអ្នកចូលរួមចំនួន ៥៣ នាក់ តាមប្រព័ន្ធអនឡាញ។

### ២.១ មតិស្វាគមន៍ និងបើកកម្មវិធី

មតិស្វាគមន៍កម្មវិធីធ្វើឡើងដោយ **អ្នកស្រី លុយ ធារី** ប្រធានកម្មវិធីនៃអង្គការគក.ស.។ ជាដំបូង អ្នកស្រីបាន ជំរាបសួរ និងស្វាគមន៍ ដល់**លោក ហុក ម៉ុងហ៊ត** ប្រធានការិយាល័យប្រាក់សោធន និងក្រុមការងារនៃបេឡាជាតិសន្តិសុខសង្គម សមាជិក សមាជិកា បណ្ដាញថ្នាក់ខេត្ត និងម្ចាស់មូលនិធិទាំងអស់ ជាទីគោរព។



យោងតាមស្មារតីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងតាងនាមអ្នករៀបចំការងារ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ដែលតែងតែយកចិត្តទុកដាក់ សហការនិងគាំទ្រដល់កិច្ចការងាររបស់អង្គការសង្គមស៊ីវិល ដើម្បីឆ្លើយតបទៅតាមបទបញ្ញត្តិ និងក្របខណ្ឌគតិយុត្តនានា សំដៅចូលរួមក្នុងការអនុវត្តច្បាប់ អោយបានពេញលេញតួយ៉ាងការអញ្ជើញជាវាគ្មិន ក្នុងវេទិការៀនសូត្រថ្ងៃនេះជាដើម។

វេទិការៀនសូត្រស្ដីពីការគ្រប់គ្រងធនធានមនុស្សចាប់ផ្ដើមឡើងតាំងពីឆ្នាំ ២០០២ មកម្ល៉េះដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីសមាជិកក្រុមការងារគ្រប់គ្រងធនធានមនុស្សទាំង១១នាក់ (ស្ត្រី២នាក់) របស់យើង។ គំនិតដើមនៃការបង្កើតអោយវេទិការៀនសូត្រនេះឡើង ក្នុងគោលបំណងសំខាន់ៗដូចជា៖

- បង្កើនសកម្មភាពរៀនសូត្រ និងចែករំលែកនូវចំណេះដឹង ជំនាញ និងបទពិសោធន៍របស់បុគ្គលិក និងស្ថាប័ននីមួយៗ ចូលទៅក្នុងសហគមន៍អ្នកអនុវត្ត ដើម្បីធ្វើអោយការងារក្នុងវិស័យគ្រប់គ្រងធនធានមនុស្សសម្រាប់អង្គការសង្គមស៊ីវិលកាន់តែប្រសើរឡើង
- ធានាអោយអ្នកជំនាញគ្រប់គ្រងធនធានមនុស្សអាចបំពេញការងារស្របតាមអនុលោមភាពបទដ្ឋានអប្បបរមានៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ
- បង្កើត និងពង្រឹងនូវបណ្តាញសម្រាប់អ្នកអនុវត្ត និងវិជ្ជាជីវៈខាងផ្នែកគ្រប់គ្រងធនធានមនុស្ស

**អ្នកស្រី លុយ ធារី** ក៏បានធ្វើការជម្រាបជូនបន្ថែមនូវសមិទ្ធផលមួយចំនួនដែលកើតចេញពីកិច្ចសហការតាមស្មារតីភាពជាដៃគូ ដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីជំនាញនៃក្រសួងការងារ និង មន្ត្រីជំនាញនៃបេឡាជាតិសន្តិសុខសង្គម ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដូចតទៅ៖ របបថែទាំសុខភាពនៃបេឡាជាតិសន្តិសុខសង្គម ប្រាក់បំណាច់អតីតភាពការងារ ប្រភេទកិច្ចសន្យាការងារ របបប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម (ខេឧសភា) ការប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល របបប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម(ខែធ្នូ) របបប្រាក់សោធននៃបេឡាជាតិរបបសន្តិសុខសង្គម។ ជារួម នេះគឺជាការជួបជុំលើកទី៣ ដែលយើងបានអញ្ជើញវាគ្មិនពីបេឡាជាតិសន្តិសុខសង្គម មកធ្វើបទបង្ហាញស្តីពី របបប្រាក់សោធន ហើយខ្ញុំសង្ឃឹមថាវេទិកានេះ នឹងជួយអោយអង្គការសង្គមស៊ីវិលយើងយល់ដឹងកាន់តែច្បាស់ពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីដល់ថ្នាក់ដឹកនាំក្រសួង និងតំណាងបេឡាជាតិរបបសន្តិសុខសង្គម លោក ហុក ម៉ុងហ៊ត និងក្រុមការងារ និងសូមប្រសិទ្ធពរជ័យជូនសមាជិក សមាជិកា លោក លោកស្រី អ្នកនាងកញ្ញា ដែលកំពុងចូលរួមក្នុងកម្មវិធីនេះ ទាំងនៅទីនេះផ្ទាល់ និងនៅតាមប្រព័ន្ធអនឡាញ អោយជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមប្រកាសបើកកម្មវិធីចាប់ពីពេលនេះ តទៅ។

## ២.២ បទបង្ហាញ

**លោក ហុក ម៉ុងហ៊ត** ប្រធានការិយាល័យប្រាក់សោធន ធ្វើបទបង្ហាញពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ មានដូចតទៅ៖

ការបង្ហាញជារួមនៃមាតិកាសំខាន់ៗរួមមាន គោលការណ៍សន្តិសុខសង្គម កាតព្វកិច្ចចុះបញ្ជី អត្រាភាគទាន សោធនជរាភាព សោធនទុព្វលភាព វិភាជន៍បូជាសព(ប្រាក់បូជាសព) និងសោធនឧត្តរជីវី សោធនជរាភាពអយ្យកប្បញ្ញត្តិ លក្ខខណ្ឌចូលរួមតាមរបបភាគទានដោយស្ម័គ្រចិត្ត។

## ១.គោលការណ៍សន្តិសុខសង្គមផ្នែកប្រាក់សោធន

- **គោលការណ៍ក្នុងប្រទេសកម្ពុជា**

  តើរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនបង្កើតឡើងដើម្បីអ្វី ?

  - ✓ ធានាឲ្យមានសមធម៌ និងសាមគ្គីធម៌សង្គម
  - ✓ ធានាសន្តិសុខ និងស្ថេរភាពប្រាក់ចំណូលនៅពេលសមាជិក **ប.ស.ស.** ចូលនិវត្តន៍
  - ✓ ទទួលបានសេវាធានារ៉ាប់រងសុខភាពនៅពេលសមាជិក **ប.ស.ស.** ចូលនិវត្តន៍
  - ✓ អ្នកនៅក្នុងបន្ទុកអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ នៅពេលអ្នកចូលនិវត្តន៍ទទួលមរណភាព
  - ✓ អ្នកក្នុងបន្ទុកឬអ្នកចាត់ចែងបូជាសពអាចទទួលបានប្រាក់សម្រាប់បូជាសពនៅពេលអ្នកចូលនិវត្តន៍មរណភាព
  - ✓ រួមចំណែកការពារសិទ្ធិ សេរីភាពចំពោះមនុស្សវ័យចាស់។

## ២. កាតព្វកិច្ចចុះបញ្ជី

### ការចុះបញ្ជី

**សហគ្រាសបានចុះបញ្ជីរួច**

ផ្នែកហានិភ័យការងារ | ផ្នែកថែទាំសុខភាព

↓

ជាសមាជិកផ្នែកប្រាក់សោធន ដោយស្វ័យប្រវត្តិ

**សហគ្រាសមិនទាន់បានចុះបញ្ជី**

កម្មករនិយោជិតដែលធ្វើការនៅសហគ្រាសគ្រឹះស្ថានដែលកំពុងដំណើរការតែមិនទាន់បានចុះបញ្ជីនៅ **ប.ស.ស.**

↓

ត្រូវមានកាតព្វកិច្ចមកចុះបញ្ជីនៅ **ប.ស.ស.** តាមបទប្បញ្ញត្តិដែលមានចែងជាធរមាន

↓

ក្លាយជាសមាជិក **ប.ស.ស.** ផ្នែកប្រាក់សោធន

## ៣. អត្រាភាគទាន

| ឆ្នាំ | អត្រាភាគទាន | កាលបរិច្ឆេទ | កម្មករនិយោជិត | និយោជក | ប្រាក់ឈ្នួលពិតាន |
|---|---|---|---|---|---|
| ៥ឆ្នាំដំបូង | ៤% | ១០/២២-៩/២៧ | ២%<br>(២៤,០០០រៀល) ក្នុង១ខែ | ២%<br>(២៤,០០០រៀល)ក្នុង១ខែ | ១,២០០,០០០រៀល |
| ៥ឆ្នាំបន្ទាប់ | ៨% | ១០/២៧-៩/៣២ | ៤%<br>(៤៨,០០០រៀល)ក្នុង១ខែ | ៤%<br>(៤៨,០០០រៀល)ក្នុង១ខែ | |
| ១០ឆ្នាំ | ១០,៧៥% | ១០/៣២-៩/៤២ | ៥,៣៧៥%<br>(៦៤,៥០០រៀល) ក្នុង១ខែ | ៥,៣៧៥%<br>(៦៤,៥០០រៀល) ក្នុង១ខែ | |
| ១០ឆ្នាំបន្ត | ១៣,៥% | ១០/៤២-៩/៥២ | ៦,៧៥%<br>(៨១,០០០រៀល)ក្នុង១ខែ | ៦,៧៥%<br>(៨១,០០០រៀល)ក្នុង១ខែ | |
| ១០ឆ្នាំបន្ត | ១៦,២៥% | ១០/៥២-៩/៦២ | ៨,១២៥%<br>(៩៧,៥០០រៀល)ក្នុង១ខែ | ៨,១២៥%<br>(៩៧,៥០០រៀល)ក្នុង១ខែ | |

**រៀងរាល់១០ឆ្នាំ អត្រាភាគទានកើនបន្ថែម២,៧៥%**

## ៤.សោធនជរាភាព(ប្រាក់ចូលនិវត្តន៍ឬប្រាក់រំលែក)

### លក្ខខណ្ឌ

- .បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- បានបង់ភាគទានយ៉ាងតិច១២ខែ
- មានអាយុយ៉ាងតិច៦០ឆ្នាំ

### អត្ថប្រយោជន៍(តាមការលិក)

១.ទទួលបានប្រាក់សោធនប្រចាំខែ(១ខែបើក២ដង)

២.ទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

### ដោយឡែក

ករណីសមាជិក ប.ស.ស. បង់ភាគទានតិចជាង១២ ប.ស.ស.នឹងបើកប្រាក់ភាគទានដែលបង់សរុបបើកផ្តាច់តែម្តង
(ទទួលបានវិភាជន៍ជរាភាព)

## ឧទាហរណ៍ ប្រាក់ឈ្នួលជាប់ភាគទានថេរហូតដល់៣០ឆ្នាំ

| ឆ្នាំបានបង់ | អត្រាសោធន | ប្រាក់ឈ្នួល | ប្រាក់សោធនទទួលបាន | ប្រាក់ឈ្នួលពិតាន |
|---|---|---|---|---|
| ១ | ១.៧៥% | ១,២០០,០០០៛ | ២១,០០០៛ | បច្ចុប្បន្នបាន កំណត់ត្រឹមតែ១,២០០,០០០៛ |
| ២ | ៣,៥០% | ១,២០០,០០០៛ | ៤២,០០០៛ | |
| ៣ | ៥,២៥% | ១,២០០,០០០៛ | ៦៣,០០០៛ | |
| ៤ | ៧% | ១,២០០,០០០៛ | ៨៤,០០០៛ | |
| ៥ | ៨,៧៥% | ១,២០០,០០០៛ | ១០៥,០០០៛ | |
| ៦ | ១០,៥០% | ១,២០០,០០០៛ | ១២៦,០០០៛ | |
| ៧ | ១២,២៥% | ១,២០០,០០០៛ | ១៤៧,០០០៛ | |
| ៨ | ១៤% | ១,២០០,០០០៛ | ១៦៨,០០០៛ | |
| ៩ | ១៥,៧៥% | ១,២០០,០០០៛ | ១៨៩,០០០៛ | |
| ១០ | ១៧,៥០% | ១,២០០,០០០៛ | ២១០,០០០៛ | |
| ៣០ | ៤៥% | ១,២០០,០០០៛ | ៥៤០,០០០៛ | |

**ករណីប្រាក់ឈ្នួលពិតាន មានការកើនឡើង ប្រាក់សោធនដែលទទួលបានមានការកើនឡើងបន្ថែមទៀត។**

## ៥. សោធនទុព្វលភាព(ពេលធ្លាក់ខ្លួនឈឺឬគ្រោះថ្នាក់ធ្ងន់ធ្ងរ)

**លក្ខខណ្ឌ**

- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- បានបង់ភាគទានយ៉ាងតិច ៦០ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព

**អត្ថប្រយោជន៍(តាមការលិក)**

១.ទទួលបានប្រាក់សោធនប្រចាំខែ( ១ខែបើក២ដង )

២.ទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

៣. អាចទទួលបានប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែរក្សា

**ចំណាំ**

ករណីសមាជិក ប.ស.ស. បង់ភាគទានតិចជាង៣០ឆ្នាំ សន្មត់ថាបង់បាន៣០ឆ្នាំ(អត្រាសោធន៤៥%)

**សោធនទុព្វលភាព** = ៤៥% □ ១,២០០,០០០រៀល = ៥៤០,០០០ រៀល

ថៃមអ្នកថែរក្សា៥០%នៃ៥៤០.០០០រៀល =២៧០,០០០រៀល

## ៦. មរណភាពបូជាសព (ប្រាក់បូជាសព) និងសោធននិវត្តជីវី

| លក្ខខណ្ឌដើម្បីទទួលបានមរណភាពបូជាសព | |
|---|---|
| សោធនិកជរាភាព(អ្នកចូលនិវត្តន៍ស្លាប់) | សោធនិកទុព្វលភាព(អ្នកចូលនិវត្តន៍ស្លាប់) |
| វិភាជន៍បូជាសពផ្អែកប្រាក់សោធនត្រូវកំណត់ស្មើនឹង ៥ខែនៃប្រាក់សោធនចុងក្រោយរបស់សាមីខ្លួន ឬត្រូវកំណត់អប្បបរមាស្មើនឹង២,000,000រៀល | |

| លក្ខខណ្ឌដើម្បីទទួលបានសោធននិវត្តជីវី | |
|---|---|
| សោធនិកជរាភាពឬទុព្វលភាព(ទទួលមរណភាព) | សមាជិក **ប.ស.ស.** បានបង់ភាគទានផ្អែកប្រាក់សោធនយ៉ាងតិច៦០ខែ(ទទួលមរណភាព) |
| សោធននិវត្តជីវី(អ្នកមានសិទ្ធិបន្តក្នុងគ្រួសាររបស់គាត់) មានដូចជា៖ ប្តីឬប្រពន្ធ និងកូនក្នុងបន្ទុក | |

៦. វិភាជន៍បូជាសព

សោធនិកទទួលបានប្រាក់បូជាសព ដែលថវិកា នឹងត្រូវផ្តល់ជូនទៅអ្នកដែលបានជួយរៀបចំបូជាសព ដែលទទួលបានយ៉ាងតិច ២.០០០.០០០ រៀល។

**សោធននឧត្តជីវី:** បង់វិភាគទានយ៉ាងតិច បាន៦០ខែ ក្រោយមកស្លាប់។ ក្នុងករណីនេះ សហព័ទ្ធអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែបាន។ តើសហព័ទ្ធត្រូវមានលក្ខណ្ឌអ្វីខ្លះ ?

- សំបុត្រអាពាហ៍ពិពាហ៍
- មិនមានប្រាក់ចំនូល ឬប្រាក់ចំនូលទាបពីភាពក្រីក្រ

* *សម្រាប់កូនត្រូវមានលក្ខណ្ឌ

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- មានប្រាក់ចំនូលទាប ពីបន្ទាត់ភាពក្រីក្រ

ទោះយ៉ាងណា សម្រាប់កូនពិការ ឬមានជំងឺរ៉ាំរ៉ៃ អាចទទួលបានការគាំទ្ររហូត។

## ៧. សោធនជរាភាពអយ្យកប្បញ្ញត្តិ (ថែមឆ្នាំអតីតភាពប្រាក់សោធន)

សមាជិក ប.ស.ស. មានសិទ្ធិទទួលបានថែមឆ្នាំអតីតភាពប្រាក់សោធន លុះត្រាតែសមាជិកប.ស.ស.ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

1. បានចុះបញ្ជីនៅប.ស.ស.ផ្នែកប្រាក់សោធនចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២
2. មានអាយុលើស៣០ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២
3. បានបង់ភាគទានយ៉ាងតិច២៤ខែ ក្នុងរយៈពេល៣៦ខែ គិតចាប់ពីខែតុលា ឆ្នាំ២០២២ដល់ខែកញ្ញា ឆ្នាំ២០២៥។

ដើម្បីបានឆ្នាំថែមអតីតភាពប្រាក់សោធនឬឆ្នាំភាគទាន គឺយកអាយុសមាជិកពេលចុះបញ្ជីផ្នែកប្រាក់សោធនដំបូងដកនឹង៣០ចែកនឹង២។ ឧទាហរណ៍ ប.ស.ស.ថែមឆ្នាំអតីតភាពប្រាក់សោធនជូនគាត់បាន១០ឆ្នាំ មូលហេតុគឺ

**យកអាយុ៥០ឆ្នាំ-៣០ឆ្នាំ ចែកនឹង២ =១០ឆ្នាំ ។**

ឧទាហរណ៍ លោក សីហា មានអាយុ៥០ឆ្នាំ បានបង់ភាគទានមកប.ស.ស.បាន១០ឆ្នាំមានប្រាក់ខែ១,២០០,០០០រៀល។ គាត់ទទួលបានអតីតភាពសរុប២០ឆ្នាំ មូលហេតុគឺ

**យក១០ឆ្នាំ( បានបង់ជាក់ស្តែង )+១០ឆ្នាំ( ឆ្នាំដែលប.ស.ស.បន្ថែមជូន )=២០ឆ្នាំ**

ដូចនេះ គាត់មានឆ្នាំអតីតភាពសរុប២០ឆ្នាំ =៣២,៥០%។
ប្រាក់សោធនសរុប (ប្រាក់ចូលនិវត្តន៍)គឺ ៣២,៥០% □ ១,២០០,០០០រៀល=៣៩០,០០០រៀលក្នុងមួយខែ។




**មតិបិទកម្មវិធីដោយលោក លោកបណ្ឌិត ប៉ែន សារាក់នាព** នាយកគ្រប់គ្រងទូទៅនៃ5P Up2date និងជាសមាជិកក្រុមការងារបច្ចេកទេសធនធានមនុស្ស បានមានចំណាប់អារម្មណ៍ដូចតទៅ៖



ជាដំបូងខ្ញុំសូមជម្រាបសួរដល់លោកវាគ្មិន និងក្រុមការងារ ព្រមទាំងអ្នកចូលរួមទាំងផ្ទាល់និងអនឡាញ រួមទាំងក្រុមការងារនៃអង្គការគសកទាំងអស់ជាទីរាប់អាន។ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង សម្រាប់ការចែករំលែកអំពីបទបង្ហាញពីប្រាក់សោធនពីសំណាក់វាគ្មិនកិត្តិយសនៃ បសស នាពេលនេះ។ វេទិកាស្តីពីប្រាក់សោធននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ទាំងមន្ត្រីរាជការ និងវិស័យឯកជនក្នុងការអនុវត្ត។ ការធ្វើបទបង្ហាញនាពេលនេះពិតជាបានឆ្លើយតបយ៉ាងពិស្តារ ទៅនឹងចំងល់នៃអ្នកចូលរួម តែបើទោះបីជាយ៉ាងនេះក្តីក៏ខ្ញុំសង្កេតឃើញថាអ្នកចូលរួមនៅតែមានភាពសកម្មក្នុងការសួរសំណួរបន្ថែមទៀត តែដោយសារពេលវេលាយើងមានកំណត់ ដូច្នេះ ខ្ញុំសង្ឃឹមថាលោកវាគ្មិននឹងបន្តផ្តល់ឱកាសនាពេលខាងមុខទៀតសម្រាប់អោយអង្គការ គ ស ក អាចនឹងធ្វើការអញ្ជើញលោកមកធ្វើការបកស្រាយបន្ថែមទៀតនាពេលក្រោយក្នុងករណីមានការស្នើសុំច្រើនបន្ថែមទៀតពី អ្នកចូលរួម។ ឆ្លៀតក្នុងឱកាសនេះដែរ អ្វីដែលខ្ញុំបានរៀនសូត្រនឹងយល់ដឹងបន្ថែមទៀតស្តីពីប្រាក់សោធននេះ ខ្ញុំនឹងអាចធ្វើការឆ្លើយតបទៅនឹងចម្ងល់របស់បងប្អូនដទៃទៀត ហើយចំណុចណាដែលខាងខ្ញុំមិនអាចឆ្លើយជូនបាន ខ្ញុំនឹងស្នើសុំទៅអង្គការគសក ដើម្បីស្នើសុំការបកស្រាយបន្ថែមពីសំណាក់វាគ្មិន ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សំណាក់វាគ្មិន ក្រុមការងារគសក ដែលបានរៀបចំវេទិការៀនសូត្រដ៏ល្អនេះ ព្រមទាំងអរគុណដល់អ្នកចូលរួមទាំងផ្ទាល់ និងតាមរយៈអនឡាញសម្រាប់ការចូលរួមនាពេលនេះនឹងសូមជូនពរលោក លោកស្រី ទាំងអស់មានសុខភាពល្អ ចៀសផុតពីកូវីដ១៩ និងជោគជ័យគ្រប់ភារកិច្ច។

## វេទិកាសំណួរចំលើយ

១) តើបុគ្គលិករង់ចាំ VISA ដែលត្រូវទៅរស់នៅក្រៅប្រទេស តើគាត់អាចស្នើសុំទៅកាន់ បសស សម្រាប់ការមិនបង់វិភាគទានផ្នែកប្រាក់សោធន នេះបានដែរឬទេ ?

- មិនមានករណីលើកលែកនោះទេ។ ហើយសម្រាប់ប្រាក់វិភាគទានដែលបុគ្គលិករូបនោះបានបង់ក៏ បសស បើកជូនវិញដែរ។

២) បើមានករណីបុគ្គលិកផ្លាស់ប្តូរកន្លែងការងារច្រើន តើបសស នឹងធ្វើយ៉ាងណាចំពោះវិភាគទានដែលស្ថាប័នរបស់បុគ្គលិករូបនោះបានបង់ជូនគាត់រួចមកហើយនោះ ?

- សម្រាប់វិភាគទានដែលបានបង់ពីស្ថាប័នមួយទៅស្ថាប័នមួយ បសស នឹងធ្វើការបូកសរុបដើម្បីបើកជូនវិញនៅពេលដល់អាយុចូលនិវត្ត។

៣) តើបសស មានយុទ្ធការនៃការជូនដំណឹងពីការប្រែប្រួលពិដាននៃការបង់ប្រាក់វិភាគទានផ្នែកសោធន សម្រាប់បុគ្គលិកទូទៅ យ៉ាងណាដែរ ? ពីព្រោះវាអាចប៉ះពាល់ដល់ស្ថាប័នក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។

- ប្រាក់ឈ្នួលពិដាននាពេលនេះ ត្រឹម១លាន២សែន( យោងតាមអនុក្រឹត្យស្តីពី ការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន លេខ១៤៨ អនក្រ បក ចុះថ្ងៃទី១៩ សីហា ២០២១ ។ បើក្នុងករណី មានការប្រែប្រួលយ៉ាងណានោះ បសស នឹងធ្វើការជម្រាបជូនជាសាធារណៈ អំពីដំណឹងនេះ។

៤)សម្រាប់អ្នកធ្វើការដោយស្ម័គ្រចិត្ត តើតម្រូវអោយបង់វិភាគទានផ្នែកប្រាក់សោធននេះដែរឬទេ ?

- ចំពោះសហគ្រាសដែលមានបុគ្គលិកចាប់ពីម្នាក់ទៅ តម្រូវអោយនិយោជក ត្រូវតែចុះឈ្មោះជាមួយ បសស ក្នុងការបង់វិភាគទានផ្នែកប្រាក់សោធនជូននិយោជិករបស់ខ្លួន ដោយមិនកំណត់អំពីប្រភេទនៃបុគ្គលិកនោះឡើយ។ ដោយត្រូវបង់ទាំង៣ប្រភេទគឺ ហានិភ័យការងារ ថែទាំសុខភាព និងប្រាក់សោធន។ យ៉ាងណាមិញបុគ្គលិក នៅតែអាចបន្តបង់វិភាគទានដោយស្ម័គ្រចិត្តបានដោយ **គោរពលក្ខខណ្ឌទាំង៣ខាងក្រោមនេះ៖**
  - បាត់បង់ការងារមុនអាយុ៦០ ឆ្នាំ និងមានលទ្ធភាពអាចបង់បន្តបាន
  - មានអាយុ៦០ឆ្នាំ

- មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិដានដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច។

*** ចំពោះការដាក់លុយសន្សំសម្រាប់លក្ខខណ្ឌទី៣នេះ (ជាបុគ្គលដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិដាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច) បើគាត់មិនមែនជាសមាជិកបសសពីមុនមកទេ គឺគាត់មិនអាចបង់វិភាគទានបានឡើយ។ ចំពោះលក្ខខណ្ឌទី៣នេះ បើគាត់គឺជាសមាជិកនៃបសស រួចមកហើយ ដូច្នេះគាត់អាចស្ម័គ្រចិត្តក្នុងការបន្តបង់ភាគទានទៀតបាន ដោយគិតប្រាក់ឈ្នួលពិដានត្រឹមមួយលានពីរសែនរៀល ឬលើសពីនេះតាមការស្ម័គ្រចិត្តរបស់គាត់បាន តែកាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ចដែលត្រូវអនុវត្តជាមួយនិយោជកនោះគឺត្រូវអនុវត្តតាមការកំណត់របស់ច្បាប់ជាធរមាន។

៥) តើមាននីតិវិធីនៃការចុះបញ្ជី សម្រាប់សហគ្រាសថ្មី?

- មានរយៈពេល៣០ថ្ងៃ សម្រាប់ការចុះបញ្ជីទៅកាន់បសស សម្រាប់ការបង់វិភាគទានផ្នែកប្រាក់សោធន គឺគិតចាប់ពីថ្ងៃទី៥ កក្កដា ឆ្នាំ២០២២នេះតទៅ។ ប្រសិនជាមានករណីខកខានមិនបានប្រកាសបង់វិភាគទានទេនោះ ក្រុមការងារបសស នឹងមានវិធានការអនុវត្តតាមការកំណត់របស់ច្បាប់។

៦) ការវិនិយោគបន្ថែមក្រៅពីការបង់វិភាគទាន តើមានជាអត្ថប្រយោជន៍អ្វីខ្លះ? ហើយមានការគិតគូរជាអត្រាការប្រាក់ដូចធនាគារដែរឬទេ?

- ការបង់វិភាគទានដោយស្ម័គ្រចិត្ត គឺនឹងទទួលបានផលនៃការវិនិយោគ។ នាយកដ្ឋានផ្នែកវិនិយោគនៃបសស នឹងយកលុយទាំងអស់នោះទៅវិនិយោគ ហើយការវិនិយោគនីមួយៗគឺមានបែបផែនផ្សេងៗគ្នា និងមានការគិតគូរច្បាស់លាស់ពីក្រុមការងារនាយកដ្ឋានវិនិយោគ ទៅលើកញ្ចប់លុយដែលយកទៅវិនិយោគនោះ។ លទ្ធផលនៃការវិនិយោគនោះគឺនឹងផ្តល់អត្ថប្រយោជន៍ជូនគាត់ដែលមានបែបផែនស្រដៀងនឹងការប្រាក់ តែនេះគេហៅថាជាប្រាក់វិនិយោគ។ សម្រាប់អ្នកដែលវិនិយោគនោះ អាចមកកាន់ការិយាល័យផ្នែកវិនិយោគនៃបសស បានសម្រាប់ការសួរពត៌មានពីទឹកប្រាក់ដែលបានវិនិយោគ។

- សម្រាប់ប្រាក់ឈ្នួលជាប់ភាគទាន គឺយកប្រាក់ឈ្នួលមុនកាត់ពន្ធមកគិតគណនា។

៧) ការបង់វិភាគទានផ្នែកប្រាក់សោធនបានតិចជាង១២ខែ មុនចូលនិវត្តន៍ តើបសស មានផ្តល់អត្ថប្រយោជន៍លើការថែទាំសុខភាពដែរឬទេ?

- គាត់អាចបើកប្រាក់សោធនជរាភាពពីបសស(បើកផ្តាច់តែម្តងគត់ពីបសស) តែពុំមានការផ្តល់សេវាអត្ថប្រយោជន៍លើការថែទាំសុខភាព និងការថែទាំ ជូនទៀតនោះទេ។

៨) តើនិយោជកអាចបង់ប្រាក់សោធនទាំង៤% ជូនបសស ជំនួស និយោជិកបានដែរឬទេ?

- បើនិយោជិកឬថៅកែ ផ្តល់អត្ថប្រយោជន៍ខ្ពស់ជាងច្បាប់កំណត់ នោះពិតជាការប្រសើរសម្រាប់និយោជិក ហើយច្បាប់ក៏អនុញ្ញាតដែរ បើយោងតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។

៩) តើនិយោជិក អាចស្នើសុំបង់ផ្តាច់សម្រាប់ការបង់វិភាគទានផ្នែកប្រាក់សោធននេះបានដែរឬទេ?

- មិនអាចបង់ផ្តាច់សរុបតែម្តងនោះទេ គឺតម្រូវអោយបង់តាមលក្ខខណ្ឌកំណត់ដើម្បីទទួលបានអត្ថប្រយោជន៍ផ្សេងៗបន្ថែមទៀត។

១០) សម្រាប់ជនបរទេសដែលបានបង់វិភាគទានបានរយៈពេល១ឆ្នាំ ឬ២ឆ្នាំ ហើយត្រូវត្រឡប់ទៅបរទេសវិញ តើត្រូវគិតយ៉ាងណា?

- សម្រាប់ជនបរទេ នៅពេលគាត់ចូលនិវត្តន៍ ឬក៏ធ្វើដំណើរត្រឡប់ទៅបរទេសវិញ ក្រុមការងារបសស បាននឹងកំពុងពិភាក្សាគ្នាក្នុងការកំណត់នីតិវិធីដើម្បី ធ្វើការផ្ទេរប្រាក់វិភាគទានជូនពួកគាត់វិញដែរ។ បសស កំពុងបង្កើតកិច្ចសហការក្រៅប្រទេសក្នុងការផ្ទេរប្រាក់អត្ថប្រយោជន៍ ជូនដល់អ្នកនៅក្រៅប្រទេសដើម្បីអនុវត្តរបបប្រាក់សោធន នេះផងដែរ។

១១) សម្រាប់អ្នកអត់ការងារធ្វើ តើត្រូវបង់វិភាគទានទាំង៣ប្រភេទហ្នឹង ឬយ៉ាងណា?

- បើអត់ការងារធ្វើគឺមិនអាចបង់វិភាគទានលើផ្នែកហានិភ័យការងារបាននោះទេ។ តែគាត់អាចបង់លើផ្នែកប្រាក់សោធនបាន។

១២) តើការបង់ប្រាក់វិភាគទានផ្នែកប្រាក់សោធនជរាភាពមុនអាយុ៦០ឆ្នាំ តែគាត់បានស្លាប់ហើយបង់បានតិចជាង១២ខែ តើត្រូវគិតយ៉ាងណា?

- គាត់អាចទទួលបានវិភាជន៍បូជាសពផ្នែកថែទាំសុខភាព ប្រសិនបើការស្លាប់នោះក្នុងករណីដែលកាត បសសរបស់គាត់នៅមានសុពលភាព។ ចំពោះចំណុចនេះ គឺនៅក្នុងសេចក្តីព្រាងនៅឡើយ ហើយជិតចេញអោយអនុវត្តហើយ។

១៣) បើមានបុគ្គលិកនៅក្រៅប្រទេស( Head office) តែពួកគាត់គិតប្រាក់ខែនៅស្រុកខ្មែរ។ តើបសស តម្រូវអោយបុគ្គលិកដែលនៅបរទេសនោះ ត្រូវបង់វិភាគទានផ្នែកប្រាក់សោធននោះដែរឬទេ?

- សម្រាប់បុគ្គលិកដែលនៅក្រៅប្រទេស បើទោះបីជាគាត់បានទទួលប្រាក់ខែពីស្រុកខ្មែរ ការតម្រូវអោយបង់វិភាគទានប.ស.ស មិនអាចអនុវត្តទៅលើបុគ្គលិករូបនោះទេ។ ការតម្រូវអោយបង់វិភាគទានផ្នែកប្រាក់សោធននេះអនុវត្តតែចំពោះបុគ្គលិកដែលបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

១៤) បើគាត់បាត់បង់ការងារតែ គាត់ចង់បន្តបង់ភាគទានដោយស្ម័គ្រចិត្តលើផ្នែកប្រាក់សោធនតែមួយមុខ រហូតដល់អាយុ៦០ឆ្នាំ។ តើក្រៅពីអត្ថប្រយោជន៍នៃប្រាក់សោធន តើគាត់អាចទទួលបានអត្ថប្រយោជន៍ផ្នែកថែទាំសុខភាពដែរឬទេ?

- ក្នុងករណីដែលគាត់បានបង់វិភាគទានដោយស្ម័គ្រចិត្តក្នុងកំឡុងពេលគាត់បាត់បង់ការងាររហូតដល់អាយុ៦០ឆ្នាំ នោះគាត់នឹងទទួលបានប្រាក់សោធនត្រឡប់មកវិញ។ ដោយឡែកអត្ថប្រយោជន៍ផ្នែកថែទាំសុខភាពគឺគាត់ពុំទទួលបាននោះទេ។

១៥) តើបសស នឹងគិតគូរយ៉ាងណា ក្នុងករណីបុគ្គលិកណាម្នាក់ដែលបម្រើការងារច្រើនស្ថាប័នក្នុងពេលតែមួយ?

- នៅពេលបុគ្គលិកណាម្នាក់ដែលជាសមាជិក បសស ធ្វើការបំពេញការងារ២ឬ៣ស្ថាប័នហើយស្ថាប័នគាត់បានបង់វិភាគទានទៅបសស ទាំងអស់ នោះនៅពេលទូទាត់វិញ ខាងបសស នឹងគិតគូរផ្តល់ត្រឡប់ជូនវិញទាំងអស់ដោយបូកសរុប នូវវិភាគទានគ្រប់ស្ថាប័នគាត់ដែលបានបង់ជូនមក បសស ដើម្បីគណនាក្នុងការផ្តល់ជូនទៅបុគ្គលិកនោះវិញ។

១៦) ចំពោះបុគ្គលិកដែលបានបង់វិភាគទាន បសស ទាំង៣ផ្នែក (ហានិភ័យការងារ ថែទាំសុខភាព និងប្រាក់សោធន) តើការផ្តល់អត្ថប្រយោជន៍ត្រឡប់មកវិញបានទាំង៣ ឬបានតែមួយ?

- ការផ្តល់អត្ថប្រយោជន៍ត្រឡប់មកវិញចំពោះការបង់វិភាគទានទាំង៣ផ្នែក នោះនឹងគិតផ្តល់ជូនលើអត្ថប្រយោជន៍លើផ្នែកណាមួយដែលមានអត្ថប្រយោជន៍ខ្ពស់ជាងគេក្នុងចំណោមទាំង៣ផ្នែកដែលបានបង់នោះ។

១៧) តើធ្វើយ៉ាងណាដើម្បីអាចដឹងថាបុគ្គលិកនោះបានបង់វិភាគទានបានរយៈពេលប៉ុណ្ណាហើយនោះ?

- សម្រាប់ព័ត៌មាននៃការបង់វិភាគទានទៅបសស បុគ្គលិករូបនោះអាចធ្វើការពិនិត្យព័ត៌មាននៃការបង់ ការប្រើប្រាស់សេវាមន្ទីរពេទ្យ របស់សាមីខ្លួនបានតាមរយៈAPP របស់បសស ដែលបងប្អូនអាចធ្វើការដោនឡូតតាមរយៈទូរស័ព្ទដៃផ្ទាល់ខ្លួនបាន។

១៨) សម្រាប់បុគ្គលិកដែលមានវ័យលើសពី៦០ឆ្នាំ ហើយគាត់បានបង់វិភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព តែគាត់មិនបានបង់វិភាគទានផ្នែកប្រាក់សោធននៅឡើយ។ តើគាត់ត្រូវធ្វើបែបណាពេលគាត់ចង់ស្នើសុំផ្នែកប្រាក់សោធន?

- សម្រាប់សមាជិកបសស ដែលធ្លាប់បង់វិភាគទានកន្លងមកហើយមានអាយុលើសពី៦០ឆ្នាំឡើងគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ គាត់អាចមានសិទ្ធិមកស្នើសុំចុះបញ្ជីដោយស្ម័គ្រចិត្តផ្នែកប្រាក់សោធនជវាភាពអយ្យកប្បញ្ញត្តិជាមួយបសស បាន។

## ៣. ឧបសម្ព័ន្ធ

១ (បទបង្ហាញនៃវាគ្មិន)

**របៀបវារៈ**

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៧:៤០ -០៨:១៥ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គក.ស. |
| ០៨:១៥-០៨:៣០ | - ការណែនាំពី បទបញ្ជាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br><br>អង្គការ គក.ស. |
| ០៨:៣០-៨:៤០ | កិច្ចស្វាគមន៍ និងបើកកម្មវិធីដោយតំណាងអង្គការ គក.ស. | **អ្នកស្រី លុយ ធារី**<br><br>ប្រធានកម្មវិធីនៃអង្គការគក.ស. |
| ៨:៤០ -៨:៤៥ | ការថតរូបជុំគ្នា | |
| ៨:៤៥ -១០:១៥ | បទបង្ហាញស្តីពី៖ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។<br><br>• លក្ខខណ្ឌ និងតារកាលិក សោធនជរាភាព<br>• លក្ខខណ្ឌ និងតារកាលិក វិភាជន៍ជរាភាព<br>• លក្ខខណ្ឌ និងតារកាលិក សោធនទុព្វលភាព<br>• សោធនឧត្តរជីវី | **សម្របសម្រួលដោយ៖**<br><br>**ឈ្មោះ ហុក ម៉ុងហ៊ត**<br><br>ប្រធានការិយាល័យប្រាក់សោធនធន |
| ១០:១៥-១០:៣០ | សម្រាកអាហារសម្រន់ | |

| | | |
|---|---|---|
| ១០:៣០-១១:០០ | បទបង្ហាញស្តីពី៖ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។<br>• លក្ខខណ្ឌ និងតាវកាលិក សោធនជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក វិកាជន៍ជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក សោធនទុព្វលភាព<br>• សោធនឧត្តរជីវី | **សម្របសម្រួលដោយ៖**<br>**ឈ្មោះ ហុក ម៉ុងហ៊ត**<br>ប្រធានការិយាល័យប្រាក់សោធន |
| ១១:០០-១១:៥០ | **សំណួរនិងចម្លើយ** | **សម្របសម្រួលដោយ៖**<br>**លោក ជា វិបុល** អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |
| ១១:៥០-១២:០០ | បិទកម្មវិធី | **លោកបណ្ឌិត ប៉ែន សារាក់នាព** សមាជិកក្រុមការងារធនធានមនុស្សនៃអង្គការគ.ក.ស. |
| ១២:០០-១៣:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |